ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៨ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៨សម្រាប់ឆ្នាំ២០២០ តាមវីដេអូខនហ្វើរេន(Blue Jeans) ក្រោមការដឹកនាំរបស់ **ឯកឧត្តម ឈឹម ឃិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានសមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ខេត្ត អង្គការមួយចំនួនដែលពាក់ព័ន្ធ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ផ្សព្វផ្សាយជូនសមាជិកក្រុមប្រឹក្សាបច្ចេកទេសពីការអនុវត្តជាក់ស្តែងរបស់អង្គការ CRS ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេសការអភិវឌ្ឍជំនាញក្នុងការបញ្ចូលសកម្មភាពមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឈឹម ឃិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិក សមាជិកាទាំងអស់ដែលបានអញ្ជើញចូលរួមតាមរយៈវីដេអូខនហ្វើរេន( Bluejeans)តាមរបៀបវារៈដែលបានកំណត់។

**លោកវេជ្ជ. សុខ ប៊ុន** នាយករងអង្គការ CRS បានបង្ហាញពីការឆ្លើយតបទៅនឹងបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយចីរភាព និងគម្រោងគាំទ្រការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្ពោះទៅមុខក្នុងការលប់បំបាត់មេរោគអេដស៍ និងជំងឺអេដស៍ ចំពោះការឆ្លងរាលដាលថ្មីសម្រាប់ឆ្នាំ២០១៨-២០២០ ដែលបានទទួលការឧបត្ថម្ភគាំទ្រមូលនិធិពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។ ការអនុវត្តសកម្មភាពដែលបានអនុវត្តកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍មាន៥ខេត្ត ដែលគ្របដណ្តប់១១ស្រុក និង៧៨ឃុំមាន៖ ខេត្តសៀមរាបគឺស្រុកបន្ទាយស្រីមាន៦ឃុំ ខេត្តពោធិ៍សាត់គឺស្រុកក្រវ៉ាញមាន៧ឃុំ ស្រុកវាលវែងមាន៥ឃុំ ស្រុកសំពៅមាសមាន១២ឃុំ ខេត្តប៉ៃលិនគឺក្រុងប៉ៃលិនមាន៤សង្កាត់ ស្រុកសាលាក្រៅមាន៤ឃុំ ខេត្តបន្ទាយមានជ័យគឺស្រុកមង្គលបូរីមាន១៤ឃុំ ស្រុកព្រះនេត្រព្រះមាន៨ឃុំ ស្រុកភ្នំស្រុកមាន៧ឃុំ និងខេត្តព្រះវិហារគឺក្រុងព្រះវិហារមាន៦សង្កាត់ ស្រុកជាំក្សាន្តមាន៥ឃុំ។ ការងារបន្ទាប់មកទៀតគឺការផ្តល់មុខជំនាញមួយចំនួនដល់ឃុំ សង្កាត់ ដើម្បីឱ្យពួកគាត់អាចដាក់បញ្ចូលផែនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក៏ដូចជាផែនការវិនិយោគឃុំ សង្កាត់ផងដែរ។ ហើយរយៈពេលនៃការបណ្តុះបណ្តាលមានរយៈពេល១២ថ្ងៃ ដោយបានលើកយកប្រធានបទចំនួន៨មកបង្ហាញ៖

១.ស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ការចម្លង និងការការពារជំងឺអេដស៍។
២.ការរក្សាការសម្ងាត់។
៣.ការបញ្ជូនអ្នកជំងឺដើម្បីទទួលបានការផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍។
៤.ការតាមដានអ្នករស់នៅជាមួយមេរោគអេដស៍។

៥.តួនាទី និងការទទួលខុសត្រូវរបស់ក្រុមទ្រទ្រង់សុខភាពភូមិដែលមានចែងជាគោលការណ៍ ការចូលរួមរបស់សហគមន៍ និងការចែករំលែកអំពី ដីកា របស់ក្រុមទ្រទ្រង់សុខភាពភូមិ និងរចនាសម្ព័ន្ធ។

៦.ការដាក់បញ្ចូលគ្រួសារដែលមានសមាជិករស់នៅជាមួយមេរោគអេដស៍ទៅក្នុងនិតិវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

៧.ការចំណាយសេវាសង្គម និងដំណើរការទូទាត់ថវិកា(សកម្មភាពផ្នែកសុខភាព និងសកម្មភាពជំងឺអេដស៍)។

៨.ធ្វើដូចម្តេចដើម្បីដាក់បញ្ចូលសកម្មភាពសេវាសង្គម និងសកម្មភាពអាទិភាពទៅក្នុងផែនការឃុំ សង្កាត់? ដូច្នេះ ឃុំ សង្កាត់ត្រូវបង្កើតផែនការសកម្មភាពសម្រាប់សេវាសង្គម។

បន្ទាប់មកលោកក៏បានបង្ហាញអំពីមេរៀនសម្រាប់ការបណ្តុះបណ្តាលស្តីពីការបញ្ចូលសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់នៅស្រុកបន្ទាយស្រីដើម្បីសម្រេចបាននូវគោលដៅ ៩៥ ៩៥ ៩៥ ក្នុងនោះដែរ គឺមានការផ្តោតទៅលើការគាំទ្រ និងការសម្រួលវិភាជថវិកាទៅដល់ឃុំសង្កាត់ និងចំណុចសំខាន់មួយទៀតគឺការលើកកម្ពស់ការចូលរួមកម្មវិធីទ្រទ្រង់ភូមិ ឃុំ។ ម្យ៉ាងទៀតវិធីសាស្ត្រសម្រាប់បណ្តុះបណ្តាលគឺធ្វើយ៉ាងណា ដើម្បីឱ្យពួកគាត់អាចចូលរួមបាន តើត្រូវកំណត់រកតម្រូវការអ្វីខ្លះ? និងវិធីរក្សាការសម្ងាត់។ ទន្ទឹមនឹងនោះដែរក៏មានការបង្ហាញអំពីគម្រោងប្រតិបត្តិរួមបញ្ចូលគ្នាស្តីពី វិធីសាស្ត្រសកម្មភាពសហគមន៍សម្រាប់ការអនុវត្តវិធីសាស្ត្រជំរុញខ្លាំងក្លាគ្រប់គ្រងសកម្មករណីផ្ទុកមេរោគអេដស៍ និងវិធីសាស្ត្រសកម្មភាពសហគមន៍ដើម្បីអនុវត្តយុទ្ធសាស្ត្របង្កើនខ្លាំងក្លារក្សាក្នុងការទទួលបានសេវាថែទាំ និងព្យាបាល។ ចំពោះក្រុមប្រឈមមុខខ្ពស់គឺក្រុមការងារត្រូវរុករកពួកគាត់ និងនៅពេលជួបគឺត្រូវផ្តល់សេវាឱ្យទៅធ្វើតេស្តឈាមរកមេរោគអេដស៍។ នៅក្នុងកិច្ចប្រជុំ និងកម្មវិធីសំខាន់ៗមានដូចជា បណ្តាញសង្គមការធ្វើតេស្តដៃគូ និងអ្នកពាក់ព័ន្ធបានឱ្យដឹងថាអ្នករស់នៅជាមួយមេរោគអេដស៍គឺមានតម្រូវការខ្ពស់ ពិសេសអ្នករស់នៅជាមួយមេរោគអេដស៍ក្រីក្រ ដែលមានអារម្មណ៍មិនសូវនឹងនត្រូវយកចិត្តទុកដាក់ចំពោះការព្យាបាលផ្តល់ឱសថប្រឆាំងមេរោគអេដស៍។ បន្ទាប់មកទៀត លោកក៏បានបង្ហាញអំពីសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ ព្រមទាំងការណែនាំស្តីពីការកំណត់មាតិកាថវិកា និងលិខិតយុត្តិការចំណាយសម្រាប់ទូទាត់សេវាសង្គមនៅរដ្ឋបាលឃុំ សង្កាត់។

**ឯកឧត្តម** អគ្គលេខាធិការប្រធានអង្គប្រជុំក៏បានបញ្ជាក់ផងដែរថា ទោះជាបច្ចុប្បន្នស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍បានថយចុះក៏ពិតមែន ប៉ុន្តែបញ្ហាប្រឈមមុខជាមួយនឹងក្រុមប្រជាជនគន្លឹះ ពិសេសក្រុមបុរសរួមភេទជាមួយបុរស និងស្រីស្រស់ មានអត្រាឆ្លងមេរោគអេដស៍កើនឡើងខ្ពស់គួរឱ្យព្រួយបារម្ភ ម្យ៉ាងទៀតចំពោះការងារបង្ការមិនអាចបន្ធូរដៃបានទេ បើសិនជាយើងមិនយកចិត្តទុកដាក់ វានឹងផ្ទុះឡើងវិញ ព្រោះមេរោគអេដស៍មិនទាន់បានរកឃើញឱសថព្យាបាលនៅឡើយទេ។

ចុងបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំក៏បានថ្លែងអំណរគុណចំពោះលោកវេជ្ជ. សុខ ប៉ុន និងសមាជិក សមាជិកាទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំ។

**ឯកឧត្តម** ក៏បានកំណត់យកកិច្ចប្រជុំលើកក្រោយគឺថ្ងៃពុធ ១២កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ដោយបញ្ជាក់ថា នឹងរៀបចំកិច្ចប្រជុំនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំពោះសមាជិកក្រុមប្រឹក្សាបច្ចេកទេសតាមក្រសួង ដោយឡែកសម្រាប់ខេត្តគឺធ្វើតាមវីដេអូ-ខនហ្វើរេន(Blue Jeans)។

ថ្ងៃសុក្រ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

**អ្នកធ្វើរបាយការណ៍**

**ស៊ុំ ផល្លា**

បានពិនិត្យត្រឹមត្រូវ
**ប្រធាននាយកដ្ឋាន**
**ទាក់ទង និងចលនាប្រភពធនធាន**

**ហួត សេរីវុឌ្ឍ**

បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់
**អគ្គលេខាធិការ**

**ឈឹម ឃិនជាវ៉េត**